**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថាស្វាគមន៍

**របស់ទេសរដ្ឋមន្ត្រី គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ប្រធាននៃវេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (វ.ស.អ.ក) លើកទី ១**

**វិមានរដ្ឋាភិបាល, រាជធានីភ្នំពេញ,ថ្ងៃទី ១៩- ២០ ខែមិថុនា ឆ្នាំ ២០០៧**

*- សូមគោរពសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា*

*- លោកជំទាវ និងឯកឧត្តម ជាសហសេវិកក្នុងរាជរដ្ឋាភិបាល*

*- ឯកឧត្តម លោកជំទាវ ប្រធានប្រតិភូ និងតំណាងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

១- ជាបឋម ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្ស សូមសំដែងនូវកិច្ចស្វាគមន៍ចំពោះសមាជិក សមាជិកានៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានមកជួបជុំគ្នានៅវិមានរដ្ឋាភិបាលដ៏ស្កឹមស្កៃនេះ ដើម្បីប្រារព្ធវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី ១ បន្ទាប់ពីកិច្ចប្រជុំនៃគណៈ-កម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (Government-Development Partners Coordination Committee-GDCC) ប្រកបដោយជោគជ័យ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ កន្លងមក ។ មុនចាប់ផ្តើមដំណើរការវេទិការបស់យើង ខ្ញុំសូមបកស្រាយនូវមនោសញ្ចេតនារបស់អង្គវេទិកាទាំងមូល ដើម្បីសំដែងនូវកតញ្ញូតាធម៌ និងគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតជូនសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបើកវេទិកាសំរាប់កិច្ចសហប្រតិ-បត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ និងថ្លែងសុន្ទរកថាគន្លឹះ ព្រមទាំងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ សំរាប់ការងាររួមរបស់យើងទាំងអស់គ្នា ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ។

២- ឆ្នាំ២០០៧នេះ ជាឆ្នាំទី៩ ដែលប្រទេសកម្ពុជាបានរស់នៅក្នុងសន្តិភាពពេញលេញ និងឯកភាពទឹកដីជារូបវន្ត និងជាស្ថាប័ន ក្នុងបរិស្ថានស្ថេរភាពនយោបាយ ។ ទោះបីវេទិកានេះ ជាកិច្ចប្រជុំលើកទី៤ ដែល

រាជរដ្ឋាភិបាលមានកិត្តិយសរៀបចំនៅក្នុងប្រទេស ក៏វេទិកានេះគឺជាវេទិកាលើកទី១ ដែលរាជរដ្ឋាភិបាល ធ្វើជាម្ចាស់ និងដឹកនាំវេទិកានេះ ហើយជំនួសកិច្ចប្រជុំពិគ្រោះយោបល់កន្លងមក ។ រាជរដ្ឋាភិបាលបាន សំរេចផ្លាស់ប្តូរយន្តការ «កិច្ចប្រជុំពិគ្រោះយោបល់» ឱ្យទៅជា «**វេទិកាសំរាប់កិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជា**» ក្នុងឆ្នាំ២០០៧ បន្ទាប់ពីបានពិភាក្សា និងស្រុះស្រួលគ្នាជាមួយនឹងដៃគូអភិវឌ្ឍន៍ ក្នុង អំឡុងឆមាសទី២ ឆ្នាំ២០០៦ កន្លងមក ។ ដំណើរវិវត្តន៍នៃយន្តការនេះបានបង្ហាញយ៉ាងច្បាស់ នូវភាព រឹងមាំក្នុងការធ្វើជាម្ចាស់ និងជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងដំណើរការនៃកិច្ចអភិវឌ្ឍន៍ និងកម្មវិធី កំណែទម្រង់នានា ។ វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា គឺជាវេទិកាសម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ពិភាក្សាអំពីគោលនយោបាយសាធារណៈ និងការប្រកាសតួលេខណែនាំ ស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការសំរាប់រយៈពេលមធ្យម ។

*- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

៣- ជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងចន្លោះកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៦ និងវេទិកាឆ្នាំ២០០៧នេះ គឺការរក្សាបាន និងការពង្រឹងបន្ថែមទៀត នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច១០,៨% នៅឆ្នាំ ២០០៦ ដោយសារកំណើនខ្ពស់ក្នុងវិស័យកសិកម្ម ៤,៥% ទេសចរណ៍ ២២,៣% ផ្នែកវាយនភ័ណ្ឌ ២០% និងផ្នែកសាងសង់ ១៥,៧% ។ ក្នុងចន្លោះកិច្ចប្រជុំពិគ្រោះយោបល់លើកទី៨ មកវេទិកាលើកទី១នេះ ការអនុវត្តន៍គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ២០០៦ មានស្ថានភាពល្អប្រសើរ ដោយបាន កែលំអការប្រមូលចំណូល ការរឹតត្បិតចំណាយ និងការធ្វើវិចារណកម្មចំណាយលក្ខណៈជាប្រព័ន្ធ ។ ថវិកាឆ្នាំ ២០០៦ ត្រូវបានអនុវត្តយ៉ាងប្រយ័ត្នប្រយែងបំផុត ដើម្បីផ្តល់ឱកាសសម្រាប់ចំណាយជាអាទិភាពនានា ដូច ជាវិស័យអប់រំ សុខាភិបាល កំណែទម្រង់ មន្ត្រីរាជការ និងការស្តារ ការជួសជុល និងការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមទាំងប្រព័ន្ធស្រោចស្រពផងដែរ ។ កំណើនសេដ្ឋកិច្ចបាន និងកំពុងទទួល ប្រយោជន៍ពីកំណែទម្រង់នានា ដែលរាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តយ៉ាងហ្មឹងម៉ាត់ ដែលរួមមាន កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍វិស័យឯកជន ជាពិសេសការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានធុរកិច្ច និងការវិនិយោគ កិច្ចសម្រួលពាណិជ្ជកម្ម ការចូលរួម របស់វិស័យឯកជនក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម រួមជាមួយ នឹងកំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ប្រព័ន្ធច្បាប់និងតុលាការ ។ ទាំង អស់នេះ សំរេចទៅបានក្នុងសមោកាសនៃស្ថិរភាពនយោបាយ និងសុខសន្តិភាព សុទ្ធតែជាប្រការគន្លឹះបំផុត សម្រាប់កម្ពុជាបោះជំហានឆ្ពោះទៅមុខ ក្នុងការលើកកំពស់ក៏រិតជីវភាព ការគោរពសិទ្ធិមនុស្ស ការពង្រឹង លទ្ធិប្រជាធិបតេយ្យ និងការសំរេចឱ្យបាននូវកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចមានចែងក្នុងផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាឧបករណ៍សំរាប់អនុវត្ត **យុទ្ធសាស្ត្រចតុកោណ** របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។

៤- ទោះបីរាជរដ្ឋាភិបាលបានសំរេចសមិទ្ធផលជាច្រើន ក្នុងរយៈពេលមួយទស្សវត្សកន្លងទៅ ក៏ដូចជាក្នុងឆ្នាំ២០០៦កន្លងមកក៏ដោយ ក៏រាជរដ្ឋាភិបាលនៅមានបញ្ហាប្រឈមដែលត្រូវជំនះដោះស្រាយក្នុងកិច្ចអភិវឌ្ឍន៍ ។ នោះគឺការកាត់បន្ថយភាពក្រីក្រ តាមបាវចនា«សមធមិ» នៃយុទ្ធសាស្ត្រចតុកោណ ។ ថ្វីត្បិតរាជរដ្ឋាភិបាលបានខិតខំកាត់បន្ថយភាពក្រីក្រ ពី ៤៧% មកត្រឹម៣៥% ក្នុងរយៈពេលដប់ឆ្នាំមុនក៏ដោយ ក៏ការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន ពិសេសនៅតំបន់ជនបទ និងការបែងចែកប្រកបដោយសមធមិ នូវផ្លែផ្កានៃកិច្ចអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច នៅតែកង្វល់ជាប្រចាំ និងនៅតែជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ការពន្លឿនកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម ដែលកំលាំងពលកម្មជាង៧០% កំពុងពឹងផ្អែកលើវិស័យនេះ ជាអាទិភាពខ្ពស់ និងបន្ទាន់បំផុតរបស់រាជរដ្ឋាភិបាល ។ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការកាត់បន្ថយភាពក្រីក្រ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា មិនអាចសម្រេចបានឡើយ ប្រសិនបើគ្មានការបន្តបង្កើនជាដុំកំភួនទៀត នូវផលិតភាពដំណាំស្រូវ និងការបង្វែរពីផលិតផលស្រូវទៅជាដំណាំផ្សេងៗទៀតក្នុងវិស័យកសិកម្ម ព្រមទាំងឧស្សាហកម្មកែច្នៃកសិផល ។ ហេតុនេះហើយបានជារាជរដ្ឋាភិបាល បានរៀបចំបញ្ចប់យុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍវិស័យកសិកម្ម និងទឹក ។ ទន្ទឹមនេះរាជរដ្ឋាភិបាលក៏បានផ្តល់អាទិភាពខ្ពស់ ចំពោះការប្រើប្រាស់ដីធ្លី ។ រាជរដ្ឋាភិបាលដឹងច្បាស់ថា បើភាពក្រីក្រនៅតែបន្តអត្ថិភាព (Existence) ត្រាំត្រែងតទៅទៀតនោះ រាជរដ្ឋាភិបាលនឹងបាត់បង់កាលានុវត្តភាព ក្នុងការប្រើប្រាស់សក្តានុពលនៃធនធានសេដ្ឋកិច្ច និងធនធានមនុស្សដ៏មានតំលៃសំរាប់ការអភិវឌ្ឍន៍ប្រទេស ។

*- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

៥- លើសពីអ្វីៗទាំងអស់ រាជរដ្ឋាភិបាលបន្តប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ហេតុនេះហើយបានជានៅក្នុងតារាងសូចនាករថ្មីសម្រាប់ត្រួតពិនិត្យរួមគ្នា (Joint Monitoring Indicators -JMI) ការប្រជុំលើកទី១០ នៃគណៈកម្មាធិការសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ បានដាក់សូចនាករនេះជាករណីសំខាន់ ដែលត្រូវអនុវត្តបន្ត ។ អាស្រ័យហេតុនេះ សង្គ្រាមប្រឆាំងនឹងភាពក្រីក្រ និងសង្គ្រាមប្រឆាំងនឹងអំពើពុករលួយត្រូវដើរទន្ទឹមគ្នា ។ សង្គ្រាមនេះត្រូវធ្វើជាប្រចាំ ហើយវាមិនងាយនឹងមានចុងបញ្ចប់ទេ ។ បញ្ហាប្រឈមទាំងឡាយដែលបានរៀបរាប់ខាងលើបានក្លាយទៅប្រធានបទសំខាន់សំរាប់ពិភាក្សាក្នុងវេទិកានេះ ។

៦- បន្ថែមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ ដែលរាជរដ្ឋាភិបាលបានអនុមតិនាថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ដើម្បីអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ យើងក៏បានរៀបចំកម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០០៧-២០០៩ និង២០០៨-២០១០ ហើយដែរ ។ ក្រសួងផែនការបានរៀបចំរបាយការណ៍ឆ្នាំទី១នៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយលើកបញ្ជាក់ពីសមិទ្ធិផល ដែលសំរេចបាន និងបញ្ហាប្រឈម ដែលយើងទាំងអស់ត្រូវរួមគ្នាដោះស្រាយ ដើម្បីសំរេចគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងគោលបំណងឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។

*- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

៧- ការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាប្រធានបទមួយ ដែលមជ្ឈដ្ឋានអន្តរជាតិ ក៏ដូចជាប្រទេសទទួលហិរញ្ញប្បទានបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ ក្នុងរយៈពេល ៣-៤ ឆ្នាំចុងក្រោយនេះ ។ ជាក់ស្តែងនៅកម្ពុជា យើងបានអនុវត្តជំហានជាក់ស្តែងមួយចំនួនក្នុងកិច្ចការនេះរួចហើយ ។ ក្នុងរយៈពេលជិត៣ឆ្នាំកន្លងមក រាជរដ្ឋាភិបាលបានដាក់ឱ្យដំណើរការ នូវយន្តការសម្រាប់សម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ នោះគឺ ក្រុមការងារបច្ចេកទេស និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងបានពិនិត្យកែសំរួលយន្តការទាំងនេះ ក្នុងឆមាសទី២ ឆ្នាំ២០០៦ ដើម្បីពង្រឹងភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការ សំរាប់បង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ជាក់ស្តែង យើងបានប្រើប្រាស់យ៉ាងពេញលេញ នូវយន្តការទាំងនេះ សំរាប់រៀបចំការងារនានាដែលពាក់ព័ន្ធនឹងវេទិកាលើកទី១នេះ ។ លើសពីនេះ យើងបានរៀបចំបទបញ្ញត្តិមួយចំនួនដូចជា ការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សំរាប់ពង្រឹងការអនុវត្តន៍របស់យើងផងដែរ ។ ក្នុងស្មារតីនេះ សំណូមពររបស់យើងខ្ញុំ គឺគ្មានអ្វីក្រៅការអនុវត្តន៍ឱ្យបានពេញលេញ នូវសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ខែមិនា ឆ្នាំ២០០៥ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលដៃគូអភិវឌ្ឍន៍ទាំងអស់ជាហត្ថលេខីនៃសេចក្តីថ្លែងការណ៍នេះ នៅក្នុងបរិការណ៍កម្ពុជាឡើយ ។ យើងខ្ញុំសូមអបអរ ចំពោះការចុះហត្ថលេខាលើសេចក្តីប្រកាស រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការពង្រឹងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ នាថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៦ ។

៨- សំរាប់វេទិកានេះ គ.ជ.ន/ក.អ.ក បានរៀបចំរបាយការណ៍វាយតំលៃលំអិត ពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ជំនួសរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះ បានវាយតំលៃដោយផ្អែកតាមស្ថានភាពជាក់ក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ បញ្ហាប្រឈម និងអនុសាសន៍សំរាប់អនុវត្តបន្ត ។ ដៃគូអភិវឌ្ឍន៍

ជាច្រើនបានវាយតំលៃខ្ពស់អំពីគុណភាពនៃរបាយការណ៍ ហើយបញ្ហាបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានក្លាយជាកម្មវត្ថុនៃការពិភាក្សាក្នុងវេទិកានេះ ។ ខ្ញុំសូមការអនុញ្ញាតពីសម្តេចនាយករដ្ឋមន្ត្រី ដើម្បីសំដែងនូវការវាយតំលៃខ្ពស់ ចំពោះឯកឧត្តម **ឈៀង យ៉ាណារ៉ា** ដែលបានស៊ូតស៊ូញបំពេញការងារនេះ ក្នុងឋានៈជាប្រធានក្រុមការងារពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលបានរៀបចំរបាយការណ៍នេះ ។ លើសពីនេះ ឯកឧត្តមជាប្រតិបត្តិករសំខាន់មួយ ក្នុងឋានៈជាតម្រងក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានឯកភាពនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ឆ្នាំ២០០៦ សេចក្តីព្រាងតារាងសូចនាករថ្មីសំរាប់តាមដានរួមគ្នា ដែលទាំងអស់នេះគឺជារបៀបវារៈសំខាន់នៃវេទិការបស់យើង ព្រមទាំងបានដឹកនាំកិច្ចសំរបសំរួលទាំងខាងបច្ចេកទេស និងទាំងខាងរដ្ឋបាល ជាមួយនឹងបណ្តាក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលនិងជាមួយដៃគូអភិវឌ្ឍន៍ សំរាប់ដំណើរការវេទិកានេះ ។ ការវាយតំលៃនេះមិនមែនតំរង់បុគ្គលទេ តែវាស្ថិតក្នុងបរិការណ៍នៃឯកសារ «ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍» ដែលរាជរដ្ឋាភិបាលបានអនុមតិ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ហើយចង្អុលឱ្យគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ជាចំណុចប្រមូលផ្តុំនៃការសំរបសំរួលហិរញ្ញប្បទានសហប្រតិបត្តិការ ស្របតាមអនុក្រឹត្យលេខ ១៤៧ អនក្រ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ។ ការវាយតំលៃនេះក៏ឆ្លុះបញ្ចាំងផងដែរ នូវភាពជាម្ចាស់ និងភាពដឹកនាំរបស់ស្ថាប័នរបស់រាជរដ្ឋាភិបាលនេះផងដែរ ។

*- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី*

៩- វឌ្ឍនភាពដែលកម្ពុជាសំរេចបានកន្លងមក គឺបានមកពីការប្តេជ្ញាចិត្តខ្ពស់ និងសកម្មភាពជាក់ស្តែងចំទិស និងគោលដៅរបស់រាជរដ្ឋាភិបាល ក្រោមកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** រួមផ្សំជាមួយនឹងវិភាគទានដ៏ធំធេង និងធាតុចូលដ៏ថ្លៃថ្លា ពីសំណាក់ដៃគូអភិវឌ្ឍន៍ ។ វេទិកាយើងនឹងមានបុព្វសិទ្ធិ ត្រងត្រាប់ស្តាប់តាមមតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងវេទិកានេះដើម្បីបានជាទុនសំរាប់កិច្ចពិភាក្សា ។ ក្នុងន័យនេះ បន្ទាប់ពីអន្តរាគមន៍របស់លោក **IAN C. PORTER** ដែលដៃគូអភិវឌ្ឍន៍បានជ្រើសតាំងគាត់ ជាតំណាងសំរាប់វេទិកាលើកទី១នេះ យើងនឹងមានកិត្តិយស សូមគោរពអញ្ជើញសម្តេច នាយករដ្ឋមន្ត្រី ឡើងថ្លែងសន្ទរកថា និងផ្តល់សារគន្លឹះ ក្នុងឱកាសបើកវេទិកាលើកទី១នេះ ។ ខ្ញុំសូមអនុញ្ញាតអញ្ជើញលោក **IAN C. PORTER** ឡើងកាន់វេទិកា ។

**សូមអរគុណ** !